មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធខួបគម្រប់ប្រាំពីរឆ្នាំនៃមរណភាព លោកបណ្ឌិត កែម ឡី

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ គឺជាថ្ងៃខួបគម្រប់៧ឆ្នាំនៃមរណភាពរបស់លោកបណ្ឌិត កែម ឡី ជាអ្នកវិភាគនយោបាយ និងជាអ្នកតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សដ៏លេចធ្លោមួយរូប។ លោកបណ្ឌិត កែម ឡី ត្រូវបានឃាតករបាញ់សម្លាប់ទាំងព្រឹកនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ នៅស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញ។

ក្នុងឱកាសរម្លឹកខួបគម្រប់៧ឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី នេះ ម.ស.ម.ក នឹងរៀបចំព្រឹត្តិការណ៍មួយចំនួននៅក្នុងខែកក្កដា ដូចខាងក្រោម៖

១. ចាប់ពីថ្ងៃទី១៦ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា សាធារណជនអាចចូលរួមប្រកួតប្រជែងនិពន្ធ ឬតែងកំណាព្យបង្ហាញអំពីការនឹករឭកដល់លោកបណ្ឌិត កែម ឡី។

២. ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែកក្កដា ម.ស.ម.ក នឹងប្តូរគម្របទំព័រហ្វេសប៊ុករបស់ខ្លួនបច្ចុប្បន្ន ដោយដាក់តាំងបង្ហាញរូបភាពលោកបណ្ឌិត កែម ឡី ជំនួសវិញ។

៣. ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៩ ខែកក្កដា ម.ស.ម.ក នឹងបង្ហោះសម្រង់សម្តីរបស់លោកបណ្ឌិត កែម ឡី នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។

៤. នៅថ្ងៃទី០៦ ខែកក្កដា ម.ស.ម.ក នឹងរៀបចំពិធីបុណ្យទក្ខិណានុប្បទាន និងពិធីបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី នៅការិយាល័យរបស់ ម.ស.ម.ក។

៥. នៅថ្ងៃទី០៧ ខែកក្កដា ម.ស.ម.ក នឹងរៀបចំកម្មវិធីវិទ្យុពិភាក្សាលើប្រធានបទទាក់ទងនឹងយុទ្ធនាការ និងការនឹករឭកដល់លោកបណ្ឌិត កែម ឡី ព្រមទាំងមានការបង្ហោះវីដេអូស្តីពីដំណើររឿងខ្លីមួយមានចំណងជើងថា «**ពាក្យពិត**» នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ ម.ស.ម.ក តាមអ៊ីម៉ែល៖** yuthyia@cchrcambodia.org **ឬ ទូរស័ព្ទ៖ +៨៥៥ (០) ៨៨ ៨១៤ ២៧៨៣៕**

– ចប់ –

បណ្ណាធិការះ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្ស សម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ ("IFEX") ដែលជាបណ្ដាញសកលនៃសេរីភាពខាងការបញ្ចេញមតិ សម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ ("CIVICUS") និងជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម("OMCT")ជាសមាជិកនៃបណ្ដាញប្រឆាំងទារុណកម្មអែស អូ អែស និងជាសមាជិក OECD-Watch ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងនៅឆ្នាំ២០១៣ បានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីផ្លាស់ប្ដូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងការផ្លាស់ប្ដូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី៕